សហភាពអឺរ៉ុប

សំឡេង
របស់យើងដើម្បី
សមភាពយេនឌ័រ

NGO-CEDAW

# សេចក្តីប្រកាសដាក់សំណើរៈ ទីប្រឹក្សាបង្កើតស្នាដៃផ្នែកសិល្បៈ សម្រាប់ការតាំងពិព័រណ៌ នៃគម្រោងនៃសេចក្តីថ្លៃថ្នូរ ឆ្នាំ ២០១៨

**គណៈកម្មាធិការដើម្បីលប់បំបាត់រាល់ទម្រង់នៃការរើសអើងគ្រប់រូបភាពលើស្ត្រី (NGO-CEDAW) គឺជាអង្គការមិនរកប្រាក់កម្រៃដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា កំពុងធ្វើសកម្មភាពផ្តោតលើការលើកកម្ពស់សិទ្ធិមនុស្សរបស់ស្ត្រី។**

ជាផ្នែកមួយនៃយុទ្ធនាការ 16 ថ្ងៃ នៃអំពើហឹង្សាទាក់ទងនឹងយេនឌ័រ ដែលចាប់ផ្តើមនៅចុងខែវិច្ឆិកា និងទិវានារីអន្តរជាតិ នៅថ្ងៃទី 8 ខែមីនា NGO-CEDAW នឹងគាំទ្រក្នុងការបង្កើតស្នាដៃសិល្បៈជាមធ្យោបាយបង្កើនការយល់ដឹងជាសាធារណៈពីបញ្ហានានាជុំវិញអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងប្រទេសកម្ពុជា។ NGO-CEDAW ក៏កំពុងប្រើប្រាស់ស្នាដៃសិល្បៈនេះផងដែរ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងស្វែងរកមតិគាំទ្រជាបន្ត ក្នុងការស្នើអោយមានការធ្វើវិសោធនកម្មច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ដើម្បីផ្តល់ការការពារកាន់តែប្រសើរឡើងលើអំពើហឹង្សាទាក់ទងនឹងយេនឌ័រ។
NGO-CEDAW សូមអញ្ជើញអ្នកសិល្បៈកម្ពុជា ដាក់ពាក្យចូលរួមក្នុងគម្រោងនៃសេចក្តីថ្លៃថ្នូរឆ្នាំនេះ។ ក្នុងនាមជាអង្គការដែលមិនរកប្រាក់ចំណេញ NGO-CEDAW នឹងផ្តល់ប្រាក់ឧបត្ថម្ភតិចតួចក្នុងការបង្កើតឡើងនូវស្នាដៃសិល្បៈរបស់អ្នក ហើយនឹងផ្តល់ជាវេទិកាសម្រាប់ប្រើប្រាស់ក្នុងការជម្រុញឱ្យប្រជាជនកម្ពុជាផ្លាស់ប្តូរអាកប្បតិរិយាបថ និងអាកប្បកិរិយាទាំងឡាយណាដែលទាក់ទងទៅនឹងអំពើហឹង្សាសំដៅលើស្ត្រី។

**វិសាលភាពនៃការងារ**:

បើសិនបេក្ខជន/បេក្ខនារីជាសិល្បៈករ/សិល្បៈការិនី ត្រូវបានជ្រើសជ្រើសអោយចូលរួមក្នុងកម្មវិធីនេះ នឹងតម្រូវអោយបំពេញការងារដូចខាងក្រោម:
១. បង្កើតគំនិតច្នៃប្រឌិតបែបសិល្បៈ សម្រាប់ការប្រាស្រ័យទាក់ទងជាមួយសាធារណៈជន អំពីបញ្ហាអំពើហឹង្សាទាក់ទងនឹងយេនឌ័រ។
២. បង្កើតការងារសិល្បៈ (ដែលរួមមានដូចជាការបង្កើតជាអត្ថបទ ជារូបភាព ជាវីដេអូ ជារូបថត ជាក្បាច់រាំ ឬការកែច្នៃឡើងជារូបរាងវត្ថុអ្វីមួយ និងការច្នៃរួមបញ្ចូលគ្នានៃវិធីណាមួយក្នុងចំណោមវិធីទាំងនេះ) ដែលផ្តោតដោយផ្ទាល់ទៅលើបញ្ហាអំពើហឹង្សាទាក់ទងនឹងយេនឌ័រនៅក្នុងប្រទេសកម្ពុជា ។
៣. ថតរូប និងវីឌីអូអំពីដំណើរការសកម្មភាពនៃការបង្កើតស្នាដៃសិល្បៈនេះ ដែលនឹងត្រូវបានយកទៅប្រើប្រាស់ខាងក្នុងអង្គការ និងចែករំលែកជាមួយសាធារណៈជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមនិង / ឬឯកសារបោះពុម្ពនានាក្នុងគោលបំណងធ្វើការផ្សព្វផ្សាយកម្មវិធី។
៤. បានចូលរួមវគ្គបណ្តុះបណ្តាលពីរបៀបធ្វើការជាមួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
៥. ប្រឹក្សាជាមួយ NGO-CEDAW លើការបោះពុម្ពផ្សាយស្នាដៃសិល្បៈលើប្រព័ន្ធអ៊ីនធឺណែត និងការតាំងពិពរណ៍ស្នាដៃសិល្បៈនេះនៅកន្លែងសាធារណៈមួយ ឬច្រើន។
៥. ចូលរួមធ្វើការបង្ហាញស្នាដៃសិល្បៈដែលបានបង្កើតឡើងនេះនៅក្នុងកម្មវិធីតាំងពិព័ណ៌ជូនសារធារណៈជន ។

**លក្ខខណ្ឌតម្រូវនៃការដាក់ពាក្យៈ**

១. ជីវប្រវត្តិរបស់សិល្បករ និងនរណាម្នាក់ដែលធ្វើការដោយផ្ទាល់លើការបង្កើតស្នាដៃសិល្បៈ។ (ឧទាហរណ៍ប្រសិនបើអ្នក ជាក្រុមសម្តែង សូមបង្ហាញអ្នកសំដែងទាំងអស់ និងអ្នកគ្រប់គ្រង អ្នកដឹកនាំ ឬសហសេវិកទាំងអស់។ )
២. ការពិពណ៌នាអំពីស្នាដៃសិល្បៈដែលនឹងស្នើឡើង និងវិធីដែលមានការទាក់ទងនឹងប្រធានបទនៃសេចក្ដីថ្លៃថ្នូរ និងអំពើហឹង្សាទាក់ទងនឹងយេនឌ័រ។
៣. សំណើរសុំថវិកាដែលរៀបរាប់ពីចំនួនថវិកាដែលត្រូវការ (ជាប្រាក់រៀល ឬដុល្លារ) ក្នុងការបង្កើតស្នាដៃសិល្បៈ។
៤. ការពន្យល់ខ្លីអំពីមូលហេតុដែលអ្នកចង់ចូលរួមនៅក្នុងគម្រោងនៃសេចក្ដីថ្លៃថ្នូរ។

ពាក្យស្នើសុំ អាចធ្វើឡើងជាភាសាខ្មែរ ឬភាសាអង់គ្លេស។

**កាលបរិច្ឆេទឈប់ទទួលពាក្យ៖** ថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៨ ។

**ទីកន្លែងទទួលពាក្យ៖** សូមដាក់ពាក្យសុំតាមរយៈអ៊ីម៉ែលរបស់ NGO-CEDAW ngocedaw.pnh@gmai l .com ឬ តាមអាស័យដ្ឋានផ្ទះលេខ ១៦ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។